# ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣១០

## ស្តីពី

## ប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និង មន្ត្រីស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សមន្ត្រីរាជការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

### មាត្រា ១

ព្រះរាជក្រឹត្យនេះមានគោលដៅកំណត់ប្រាក់បំណាច់ស្រាវជ្រាវប្រចាំខែរបស់សមាជិកបណ្ឌិតសភា និង មន្ត្រីស្រាវជ្រាវ ដែលបំពេញមុខងារស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មាត្រា ២.-

ប្រាក់បំណាច់ស្រាវជ្រាវប្រចាំខែរបស់សមាជិកបណ្ឌិតសភា ត្រូវបានកំណត់ដូចខាងក្រោម :

ក-សមាជិកពេញសិទ្ធិ ទទួលបានប្រាក់បំណាច់ចំនួន ២ ១០០ ០០០ រៀល

ខ-សមាជិកបម្រុង ទទួលបានប្រាក់បំណាច់ចំនួន ១ ៤០០ ០០០ រៀល ។

មាត្រា ៣.-

ប្រាក់បំណាច់ស្រាវជ្រាវប្រចាំខែ ត្រូវបានផ្តល់ជូនមន្ត្រីដែលបំពេញមុខងារស្រាវជ្រាវ ហើយដែលមានសញ្ញាប័ត្រ ចាប់ពីបរិញ្ញាប័ត្រជាន់ខ្ពស់ឡើងទៅ ។

ប្រាក់បំណាច់នេះ ត្រូវបានផ្តល់ទៅតាមកម្រិតសញ្ញាប័ត្រ និងអតីតភាពសញ្ញាប័ត្រជា ៥ កម្រិត ដូចខាងក្រោម :

ក.មន្ត្រីស្រាវជ្រាវដែលមានបរិញ្ញាប័ត្រជាន់ខ្ពស់

-កម្រិត ១-អតីតភាពចាប់ពី ១២ ឆ្នាំឡើងទៅ ទទួលបានប្រាក់បំណាច់ ៩៧៦ ០០០ រៀល

-កម្រិត ២-អតីតភាពចាប់ពី ៩ ឆ្នាំដល់ ១២ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៨៤៨ ៧០០ រៀល

-កម្រិត ៣-អតីតភាពចាប់ពី ៦ ឆ្នាំដល់ ៩ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៧៣៨ ០០០ រៀល

-កម្រិត ៤-អតីតភាពចាប់ពី ៣ ឆ្នាំដល់ ៦ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៦៤១ ៧០០ រៀល

-កម្រិត ៥-អតីតភាពក្រោម ៣ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៥៥៨ ០០០ រៀល ។

ខ.មន្ត្រីស្រាវជ្រាវដែលមានសញ្ញាប័ត្រថ្នាក់បណ្ឌិត

-កម្រិត ១-អតីតភាពចាប់ពី ៩ ឆ្នាំឡើងទៅ ទទួលបានប្រាក់បំណាច់ ១ ១៣៣ ៥០០ រៀល

-កម្រិត ២-អតីតភាពចាប់ពី ៧ ឆ្នាំដល់ ៩ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៩៨៥ ៦០០ រៀល

-កម្រិត ៣-អតីតភាពចាប់ពី ៥ ឆ្នាំដល់ ៧ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៨៥៧ ០០០ រៀល

-កម្រិត ៤-អតីតភាពចាប់ពី ៣ ឆ្នាំដល់ ៥ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៧៤៥ ២០០ រៀល

-កម្រិត ៥-អតីតភាពក្រោម ៣ ឆ្នាំ ទទួលបានប្រាក់បំណាច់ ៦៤៨ ០០០ រៀល ។

មាត្រា ៤.-

ការអនុវត្តប្រាក់បំណាច់ស្រាវជ្រាវ ត្រូវកំណត់ដោយបទបញ្ញត្តិដោយឡែកស្តីពី លក្ខន្តិកៈសមាជិកបណ្ឌិតសភា និង លក្ខន្តិកៈមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៥.-

ការកែប្រែប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

មាត្រា ៦.-

សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវដែលមានមុខងារច្រើន ត្រូវទទួលបានប្រាក់បំណាច់តែមួយ

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

ប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៧ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស/រកត.០៧០៧.៣៣៣*

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧*

លេខ: ៣៦១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចាន់ថុន**